**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

មន្ទីរសុខាភិបាល ខេត្តកណ្តាល

ក្រុមលទ្ធកម្ម

លេខ ...................សជណ.កល

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

## ការងារសាងសង់អគារមណ្ឌលសុខភាព ក្រាំងម្កាក់ ឆ្នាំ២០១៧

**មន្ទីរសុខាភិបាល ខេត្តកណ្តាល** សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន ឬ សហគ្រាស(គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា **មន្ទីរសុខាភិបាល ខេត្តកណ្តាល** នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារសាងសង់អគារ **មណ្ឌលសុខភាពក្រាំងម្កាក់ ឆ្នាំ ២០១៧** ។

**មន្ទីរសុខាភិបាលខេត្តកណ្តាល** បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនឬសហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្ម ដែលមានអាសយដ្ឋាន ផ្លូវលេខ ១០៧ ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ចាប់ពីថ្ងៃ ទី២៦ ខែកញ្ញា ឆ្នាំ ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនក្រុមលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៦ខែ តុលា ឆ្នាំ២០១៧ វេលាម៉ោង ៣:០០ នាទី ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្មតាមអាសយដ្ឋានខាងលើថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០១៧ វេលាម៉ោង ៣:០០ នាទី ។

ក្រុមហ៊ុនឬសហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន ឬសហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

កណ្តាល ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១៧

**ប្រធានមន្ទីរសុខាភិបាលខេត្ត និងជា**

**ប្រធានក្រុមលទ្ធកម្ម**

វេជ្ជបណ្ឌិត **គួយ ប៊ុនធឿន**

<u>ចម្លងជូន៖</u>

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ

ទំព័រ 3